GMAC

Garment Manufacturers Association in Cambodia

# សេចក្តីថ្លែងការណ៍

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) សំដែងនូវការសោកស្តាយយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចលើប្រាក់ឈ្នួលអប្បបរមាថ្មីក្នុងកម្រិត១២៣ដុល្លារ ហើយដែលក្រោយមករាជរដ្ឋាភិបាលបានសម្រេចដោយឯកតោភាគីបន្ថែម៥ដុល្លារទៀត ធ្វើឲ្យប្រាក់ឈ្នួលអប្បបរមាថ្មីសម្រាប់អនុវត្តចាប់ពីខែមករាឆ្នាំ២០១៥ឡើងដល់ចំនួន១២៨ដុល្លារ។ ការដាក់តួលេខថ្មីចំនួន១២៣ដុល្លារសម្រាប់ធ្វើការបោះឆ្នោតនិងការបន្ថែម៥ដុល្លារបន្ថែមទៀត ជាការទាត់ចោលទាំងស្រុងនូវលទ្ធផលរបស់ក្រុមការងារត្រីភាគីពិសេស៩-៩-៩ ដែលបានធ្វើការប្រជុំពិភាក្សាយ៉ាងស្វិតស្វាញក្នុងចន្លោះពីថ្ងៃ២០ តុលា ដល់ថ្ងៃទី៣០ តុលា ដែលបានសម្រេចយកតួលេខពីរគឺ១១០ដុល្លារ និង១២១ដុល្លារ សម្រាប់ជាការពិភាក្សាចុងក្រោយ។

ការកំណត់ថ្មីនេះមានអត្រាកំណើន២៨ភាគរយបន្ថែមលើអត្រាកំណើន២០ភាគរយដែលទើបតែបានធ្វើឡើងនៅដើមឆ្នាំ២០១៤។ ការសម្រេចដំឡើងយ៉ាងគំហុកបែបនេះប្រាកដណាស់នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពអាចរស់រានមានជីវិតបានរបស់រោងចក្រជាច្រើនដែលជាសមាជិករបស់GMAC ជាពិសេសរោងចក្រដែលមានលទ្ធភាពផ្នែកហិរញ្ញវត្ថុទន់ខ្សោយនិងមានមូលដ្ឋានបញ្ញាទិញមិនរឹងមាំ។ ក្នុងអំឡុងពេលនៃការចរចារយៈពេលជាច្រើនខែចុងក្រោយមកនេះ GMACបានព្យាយាមអស់ពីសមត្ថភាពរួចហើយក្នុងការពន្យល់ដល់ភាគីពាក់ព័ន្ធអំពីផលអវិជ្ជមាននៃការដំឡើងជាគំហុកនេះ។

បន្ថែមពីប្រាក់ឈ្នួលអប្បបរមា១២៨ដុល្លារ នៅមានអត្ថប្រយោជន៍ផ្សេងៗទៀតដែលតម្រូវដោយច្បាប់ដូចជា ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅចំនួន៧ដុល្លារនិងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន១០ដុល្លារទៀត។ សរុបមក ចំនួនប្រាក់អប្បបរមាដែលកម្មករទទួលបានសម្រាប់ការងារធម្មតា៨ម៉ោងក្នុងមួយថ្ងៃនឹងឡើងដល់កម្រិត១៤៥ដុល្លារបាត់ទៅហើយ ដែលចំនួននេះស្មើនឹងប្រាក់ឈ្នួលអប្បបរមានៅតំបន់ថ្លៃបំផុតនៃប្រទេសវៀតណាម(តំបន់ទី១) ហើយស្ទើរតែពីរដងនៃប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសបង់ក្លាដែសនិងមីយ៉ាន់ម៉ា។ នេះនៅមិនទាន់គិតដល់ប្រាក់លើកទឹកចិត្តផ្សេងៗដូចជា ប្រាក់អតីតភាព ប្រាក់ធ្វើការថែមម៉ោង ប្រាក់ថ្លៃបាយ ប្រាក់ជំនាញ ប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ និងប្រាក់ធានារ៉ាប់រងសុខភាព។

ដោយមានចំនួនថ្ងៃឈប់សម្រាកសាធារណៈច្រើនលើសលុប២៧ថ្ងៃក្នុងមួយឆ្នាំ គួបផ្សំនឹងថ្លៃចំណាយខ្ពស់លើផ្នែកផ្សេងៗដូចជា អគ្គិសនី ការដឹកជញ្ជូន និងការចំណាយក្រៅផ្លូវការ ព្រមទាំងកង្វះស្ទើរតែទាំងស្រុងនៃវត្ថុធាតុដើម និងផលិតភាពទាបរបស់កម្មករ វិស័យកាត់ដេរនិងស្បែកជើងរបស់កម្ពុជាប្រាកដណាស់នឹងបាត់បង់សមត្ថភាពប្រកួតប្រជែងនិងភាពទាក់ទាញការវិនិយោគថ្មីៗ។

ដើម្បីបន្ធូរបន្ថយនូវសម្ពាធដ៏ធ្ងន់ធ្ងរដែលកើតចេញពីការដំឡើងប្រាក់ឈ្នួលអប្បបរមានេះ GMAC អំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលមេត្តាដាក់ចេញនូវគោលនយោបាយគាំទ្រនានាដើម្បីជួយដល់វិស័យទាំងពីរនេះ។ GMAC ស្នើផងដែរដល់សហជីពនានាមេត្តាកុំបង្កភាពចលាចលថែមទៀតដល់វិស័យនេះតាមរយៈការធ្វើបាតុកម្ម កូដកម្មដែលប្រាស់ចាកនឹងនីតិវិធីច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា GARMENT MANUFACTURERS ASSOCIATION IN CAMBODIA សមាគមកាត់ដេរនៅកម្ពុជា